**ព័ត៌មានសំខាន់**
**អំពីអត្ថប្រយោជន៍ផ្សេងៗរបស់អ្នក និងអំពើហិង្សាក្នុងគ្រួសារ**

# អំពើហិង្សាក្នុងគ្រួសារ

## អ្នកមានសិទ្ធិមានសុវត្ថិភាព



## ខ្សែទូរស័ព្ទបន្ទាន់ 24 ម៉ោង

| County ខោនធី | Hotline number លេខទូរស័ព្ទបន្ទាន់ | County ខោនធី | Hotline number លេខទូរស័ព្ទបន្ទាន់ |
|---|---|---|---|
| Adams | 800-799-7233 | Lackawanna | 800-799-7233 |
| Allegheny | 800-799-7233 | Lancaster | 800-799-7233 |
| Armstrong | 724-548-8888 | Lawrence | 800-799-7233 |
| Beaver | 877-629-1841 | Lebanon | 866-686-0451 |
| Bedford | 814-623-7664 | Lehigh | 877-438-4957 |
| Berks | 800-799-7233 | Luzerne | 570-823-7312 |
| Blair | 814-944-3585 | Lycoming | 570-323-8167 |
| Bradford | 800-799-7233 | McKean | 814-368-6325 |
| Bucks | 800-799-7233 | Mercer | 724-981-1457 |
| Butler | 724-776-6790 | Mifflin | 888-810-2444 |
| Cambria | 814-536-5361 | Monroe | 866-421-4200 |
| Cameron | 800-226-4759 | Montgomery | 215-643-3150 |
| Carbon | 800-799-7233 | Montour | 800-799-7233 |
| Centre | 800-799-7233 | Northampton | 877-438-4957 |
| Chester | 610-431-1430 | Northumberland | 570-644-4488 |
| Clarion | 800-799-7233 | Perry | 800-799-7233 |
| Clearfield | 800-799-7233 | Philadelphia | 800-799-7233 |
| Clinton | 800-799-7233 | Pike | 877-296-7878 |
| Columbia | 800-799-7233 | Potter | 877-334-3136 |
| Crawford | 814-333-9766 | Schuylkill | 570-622-6220 |
| Cumberland | 717-258-4249 | Snyder | 570-523-6482 |
| Dauphin | 717-238-7273 | Somerset | 800-799-7233 |
| Delaware | 800-799-7233 | Sullivan | 570-946-4215 |
| Elk | 800-226-4759 | Susquehanna | 800-799-7233 |
| Erie | 800-799-7233 | Tioga | 800-799-7233 |
| Fayette | 800-791-4000 | Union | 570-523-6482 |
| Forest | 800-799-7233 | Venango | 800-243-4944 |
| Franklin | 717-264-4444 | Venango | 814-677-7273 |
| Fulton | 800-799-7233 | Warren | 814-726-1030 |
| Greene | 800-799-7233 | Washington | 724-223-9190 |
| Huntingdon | 800-799-7233 | Wayne | 570-253-4401 |
| Indiana | 724-349-4444 | Westmoreland | 724-836-1122 |
| Jefferson | 800-799-7233 | Wyoming | 866-206-9050 |
| Juniata | 888-810-2444 | York | 717-846-5400 |

**លេខខ្សែទូរស័ព្ទបន្ទាន់សម្រាប់អំពើហិង្សាក្នុងគ្រួសារជាតិ**

1-800-799-SAFE (7233) ឬ TTY 1-800-787-3224

ការទូរស័ព្ទហៅទៅលេខខ្សែទូរស័ព្ទបន្ទាន់ជាតិ

នឹងភ្ជាប់លោកអ្នកដោយផ្ទាល់ទៅកាន់ខ្សែទូរស័ព្ទបន្ទាន់នៃកម្មវិធីប្រចាំតំបន់របស់លោកអ្នក។

# តើអំពើហិង្សាក្នុងគ្រួសារគឺជាអ្វី?

អំពើហិង្សាក្នុងគ្រួសារ កើតមានឡើងនៅពេលដែលជនណាម្នាក់នៅក្នុងគ្រួសាររបស់អ្នក ត្រូវបានយាយី ឬគំរាមកំហែងដោយសមាជិកគ្រួសារណាម្នាក់ទៀត។ បុគ្គលដែលធ្វើការយាយីនេះ អាចជាដៃគូ ប្តីប្រពន្ធ អតីតប្តីប្រពន្ធ ឬជនណាផ្សេងទៀតដែលអ្នកចាត់ទុកថាជាចំណែកនៃគ្រួសាររបស់អ្នក។ អំពើហិង្សាក្នុងគ្រួសារ គឺការវាយដំ ការធ្វើឱ្យឈឺចាប់ ការគំរាមកំហែង ឬការធ្វើឱ្យអ្នកភ័យខ្លាច ដោយតាមដានអ្នក ឬរារាំងអ្នកពីការធ្វើដំណើរទៅណាមកណាដោយសេរី។

## អ្នក និងគ្រួសាររបស់អ្នក ត្រូវទទួលបានជំនួយជាសំងាត់ ដោយមិនគិតថ្លៃ។

pennsylvania
DEPARTMENT OF PUBLIC WELFARE

CM 305-C 4/13

## សូមទាក់ទងភ្នាក់ងារអំពើហិង្សាក្នុងគ្រួសារប្រចាំតំបន់របស់អ្នក។

មានមនុស្សជាច្រើននៅក្នុងសហគមន៍របស់អ្នក ដែលអាចជួយបាន។ បើសិនជាអ្នក ឬអ្នកណាម្នាក់ដែលអ្នកស្គាល់ កំពុងរស់នៅមានអំពើហិង្សាក្នុងគ្រួសារ សូមទាក់ទងទៅកាន់ភ្នាក់ងារអំពើហិង្សាក្នុងគ្រួសារប្រចាំតំបន់របស់អ្នក ដែលមានបង្ហាញនៅក្នុងខិត្តប័ណ្ណនេះ។ ភ្នាក់ងារអំពើហិង្សាក្នុងគ្រួសារ ផ្តល់កន្លែងស្នាក់នៅ ការពិគ្រោះ សេវាកម្មផ្នែកច្បាប់ ការធ្វើផែនការសុវត្ថិភាព និងជំនួយផ្សេងៗទៀតដោយមិនគិតថ្លៃ។ អ្នកក៏អាចទាក់ទងការិយាល័យសេវាកម្មផ្នែកច្បាប់ប្រចាំតំបន់របស់អ្នក ដើម្បីយល់ដឹងពីសិទ្ធិផ្នែកច្បាប់របស់អ្នកផងដែរ។ ទាំងភ្នាក់ងារអំពើហិង្សាក្នុងគ្រួសារ និងសេវាកម្មផ្នែកច្បាប់ ផ្តល់នូវសេវាកម្ម ***ដោយមិនគិតថ្លៃ និងសំងាត់***។

## សូមទំនាក់ទំនងការិយាល័យសុខុមាលភាព ឬការិយាល័យជំនួយទីក្រុងប្រចាំតំបន់របស់អ្នក។

នៅខណៈពេលដែលអ្នកមិនត្រូវបានតម្រូវឱ្យរាយការណ៍ពីអំពើហិង្សាក្នុងគ្រួសារ នោះអ្នកអាចចង់និយាយទៅកាន់បុគ្គលិកកាន់សំណុំរឿង ដើម្បីទទួលបានជំនួយ។ បន្ទាប់ពីនិយាយជាមួយបុគ្គលិកកាន់សំណុំរឿងរបស់អ្នកហើយ អ្នកអាចត្រូវបានលើកលែងឱ្យរួចផុតពីវិធានស្តីពីសុខុមាលភាពថ្មីៗមួយចំនួន បើសិនជាវិធានដូចខាងក្រោមទាំងនោះ ធ្វើឱ្យអ្នក ឬកូនៗរបស់អ្នកស្ថិតក្នុងគ្រោះថ្នាក់នៃអំពើហិង្សាក្នុងគ្រួសារ។ សូមចងចាំថា ព័ត៌មានទាំងឡាយណាដែលអ្នកចែករំលែកជាមួយបុគ្គលិកកាន់សំណុំរឿងអំពីអំពើហិង្សាក្នុងគ្រួសារ គឺមានលក្ខណៈសំងាត់។ ទោះបីជាយ៉ាងណា អ្នកត្រូវតែយល់ដឹងថា យើងត្រូវបានតម្រូវដោយច្បាប់ ឱ្យរាយការណ៍ពីការរំលោភបំពានលើកុមារ ទៅឱ្យភ្នាក់ងារកុមារ និងយុវជននៃទីក្រុងប្រចាំតំបន់របស់អ្នក។

***វិធានសុខុមាលភាពខាងក្រោម អាចមិនអនុវត្តចំពោះគ្រួសារទាំងឡាយ ដែលកំពុងរស់នៅដោយមានអំពើហិង្សាក្នុងគ្រួសារ :***

- ***ការងារ***
  អ្នកអាចត្រូវបានលើកលែងជាបណ្តោះអាសន្នពីការងារ ការស្វែងរកការងារ ការទៅសាលារៀន ឬ ការចូលរួមវគ្គបណ្តុះបណ្តាលសំរាប់ការងារ បើសិនជាសកម្មភាពទាំងអស់នេះ ធ្វើឱ្យអ្នក ឬកូនរបស់អ្នកស្ថិតក្នុងគ្រោះថ្នាក់នៃអំពើហិង្សាក្នុងគ្រួសារ។
- ***ការគាំពារកុមារ***
  អ្នកអាចត្រូវបានលើកលែងឱ្យរួចផុតពីវិធាននៃការគាំពារកុមារមួយចំនួន បើសិនជាការផ្តល់ព័ត៌មានអំពីឪពុកនៃកូនរបស់អ្នក ឬការប្តឹងឡើងតុលាការសំរាប់ការគាំពារកុមារ ធ្វើឱ្យអ្នក និងគ្រួសាររបស់អ្នកស្ថិតក្នុងគ្រោះថ្នាក់។ អ្នកក៏អាចត្រូវបានលើកលែងឱ្យរួចផុតពីការកំណត់អត្តសញ្ញាណឪពុកនៃកូនរបស់អ្នក បើសិនជាកូនរបស់អ្នកកើតដោយសារតែអ្នកត្រូវបានចាប់រំលោភ ឬបំពាន។
- ***ឪពុកម្តាយជាក្មេងជំទង់***
  បើសិនជាអ្នកគឺជាឪពុកម្តាយដែលមិនបានរៀបការស្ថិតក្រោមអាយុ 18 ឆ្នាំ នោះអ្នកអាចមិនត្រូវបានតម្រូវឱ្យរស់នៅជាមួយឪពុកម្តាយរបស់អ្នក ឬជនពេញវ័យផ្សេងទៀតទេ បើសិនជាការរស់នៅជាមួយជននោះ គឺមានគ្រោះថ្នាក់ដល់អ្នក ឬកូនរបស់អ្នក។
- ***ការកំណត់ពេលវេលា***
  អ្នកអាចត្រូវបានលើកលែងរួចផុតពីការកំណត់ពេលវេលាជំនួយជាសាច់ប្រាក់ជាក់លាក់។

យើងដឹងថា ការនិយាយអំពីអំពើហិង្សាក្នុងគ្រួសារ គឺមានលក្ខណៈផ្ទាល់ខ្លួនណាស់។ បើសិនជាអ្នកចង់ប្រាប់យើងពីការរំលោភបំពាន សូមស្នើសុំនិយាយទៅកាន់បុគ្គលិកកាន់សំណុំរឿងរបស់អ្នកជាលក្ខណៈឯកជន។

អ្នកអាចប្រាប់បុគ្គលិកកាន់សំណុំរឿងរបស់អ្នកអំពីអំពើហិង្សាក្នុងគ្រួសារនៅគ្រប់ពេល សូម្បីតែអ្នកអាចរកឃើញថា វាលំបាកនិយាយអំពីបញ្ហានេះនាពេលនេះក៏ដោយ។ វាមានសារៈសំខាន់ក្នុងការទទួលបានជំនួយ។ ទោះបីជាអ្នកប្រាប់បុគ្គលិកកាន់សំណុំរឿងរបស់អ្នកអំពីអំពើហិង្សា ក្នុងគ្រួសារនៅថ្ងៃក្រោយក៏ដោយ អ្នកនៅតែអាចត្រូវបាន់លើកលែងចេញពីវិធានសុខុមាលភាពជាក់លាក់នៅពេលនោះ។

***សូមហៅទូរស័ព្ទទៅកាន់លេខ 911 បើសិនជាអ្នកស្ថិតនៅក្នុងគ្រោះថ្នាក់ភ្លាមៗ!***